**គណបក្សប្រជាជនកម្ពុជា**

គណៈកម្មាធិការកណ្តាល

លេខ : ១២៣៩/១៥ សស.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ

អព្យាក្រឹត និង វឌ្ឍនភាពសង្គម

*ភ្នំពេញ,ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥*

# សេចក្តីសម្រេច

## ស្តីពី

## តួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំងនិងរបៀបរបបធ្វើការ របស់គណៈចលនាស្ត្រីនៃគណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល

**យោង**: - សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលលេខ៣២៧/១៥សស.គក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីតួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល

- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៥

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលសម្រេច

**ប្រការ១៖** គណៈចលនាស្ត្រី អក្សរកាត់ "គចស"មានតួនាទីជាសេនាធិការរបស់គណៈចលនាមហាជន ក្នុងការដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តការកិច្ចរបស់អង្គការចាត់តាំង យន្តការ និងក្រុមការងារទាំងអស់របស់គណបក្ស ដែលបំពេញការងារចលនាស្ត្រី ដើម្បីធានាបាននូវសុខដុមនីយកម្មការងារចលនាស្ត្រី ក្រោមការដឹកនាំរួមរបស់គណបក្ស ។

**ប្រការ២៖** គណៈចលនាស្ត្រីមានភារកិច្ច៖

១-ផ្តួចផ្តើមគំនិតនិងផ្តល់យោបល់ជូនគណៈចលនាមហាជនដើម្បីកំណត់សម្រេចគោលនយោបាយនិងគោលការណ៍នានាសំដៅប្រមូលផ្តុំកម្លាំងគាំទ្រគណបក្ស ។

២-ពង្រឹងការដឹកនាំ គ្រប់គ្រង បណ្តុះបណ្តាលសមត្ថភាព សម្របសម្រួល ណែនាំ តម្រង់ទិស ត្រួតពិនិត្យនិងកែលម្អជាប្រចាំ ដើម្បីធានាបាននូវគុណភាពនិងប្រសិទ្ធភាពការងាររបស់គណៈចលនាស្ត្រីទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន។

៣-កសាងផែនការសកម្មភាពការងាររបស់គណៈចលនាស្ត្រី ដើម្បីចាត់តាំងអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនឲ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព។

៤-ពិនិត្យ តាមដានសកម្មភាពសង្គមពាក់ព័ន្ធ និងស្ថានភាពរបស់ស្ត្រី ដើម្បីមានវិធានការឆ្លើយតបជាក់ស្តែងឲ្យបានសមស្របទាន់ពេលវេលាតាមគ្រប់រូបភាព ។

៥-សហការជាមួយគ្រប់អង្គការចាត់តាំងគណបក្ស ស្ថាប័ននានាគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ និងសប្បុរសជន ដើម្បីកៀរគរធនធាននិងការគាំទ្រតាមមធ្យោបាយផ្សេងៗសម្រាប់បម្រើឲ្យការអនុវត្តផែនការនិងគោលនយោបាយរបស់គណបក្ស។

៦-រៀបចំគោលការណ៍ណែនាំ កំណត់តួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ក្រុមចលនាស្ត្រី។

៧-ធ្វើរបាយការណ៍ និងបូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ជូនគណៈចលនាមហាជន។

៨-បំពេញភារកិច្ចផ្សេងទៀតដែលគណៈចលនាមហាជនប្រគល់ជូន។

**ប្រការ៣៖** រចនាសម្ព័ន្ធរបស់គណៈចលនាស្ត្រី៖

រចនាសម្ព័ន្ធរបស់គណៈចលនាស្ត្រីមាន២ ថ្នាក់ គឺ ៖

១- ថ្នាក់កណ្តាល ហៅថា **គណៈចលនាស្ត្រី**

២- ថ្នាក់រាជធានី ខេត្ត ក្រសួង ស្ថាប័ន ហៅថា **ក្រុមចលនាស្ត្រី**

ថ្នាក់នីមួយៗ មានប្រធាន០១រូប អនុប្រធាននិងសមាជិកមួយចំនួនតាមការចាំបាច់។

នៅក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវមានសមាជិកគណៈកម្មាធិការគណបក្ស០១ រូបទទួលការងារចលនាស្ត្រី។

គណៈចលនាស្ត្រី មានលេខាធិការដ្ឋានជាជំនួយការ ដែលមានសមាសភាពប្រធាន ០១ រូប អនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់ ។

**ប្រការ៤៖** របៀបរបបធ្វើការរបស់គណៈចលនាស្ត្រី៖

គណៈចលនាស្ត្រីធ្វើការតាមរបបសមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ ។ រាល់ការសម្រេចត្រូវគោរពតាមមតិភាគច្រើនដាច់ខាត។

របបប្រជុំមួយខែម្តង ក្នុងករណីចាំបាច់បន្ទាន់អាចកោះប្រជុំនិងសុំយោបល់ណែនាំពីថ្នាក់លើ។

ប្រធាននិងអនុប្រធានបំពេញភារកិច្ចប្រចាំការ ដើម្បីដោះស្រាយការងារប្រចាំថ្ងៃតាមការប្រគល់សិទ្ធិពីគណៈចលនាមហាជន។

សមាជិកគណៈចលនាស្ត្រី ត្រូវបំពេញភារកិច្ចតាមមុខងារដែលបានប្រគល់ជូន។

**លេខាធិការដ្ឋាន**មានភារកិច្ច៖

- ទទួលពិនិត្យនិងចាត់ចែងនូវរាល់លិខិតចេញចូល និងគ្រប់គ្រងឯកសារ។
- ទំនាក់ទំនង សហការ ពិនិត្យ និងដោះស្រាយបញ្ហានានា ជាមួយគណៈចលនាចំណុះគណៈចលនាមហាជន ស្ថាប័នពាក់ព័ន្ធនានា និងក្រុមចលនាស្ត្រីគ្រប់លំដាប់ថ្នាក់។
- រៀបចំផែនការសកម្មភាពនិងគម្រោងថវិកា។

- រៀបចំកិច្ចប្រជុំ សិក្ខាសាលា សន្និបាត ការងារពិធីការផ្សេងៗ និងធ្វើកំណត់ហេតុ។
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បំពេញភារកិច្ចផ្សេងទៀតដែលគណៈចលនាស្ត្រីប្រគល់ជូន ។

**ប្រការ៥៖** ខុទ្ទកាល័យ គណៈចាត់តាំង គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល គណៈចលនាស្ត្រីនិងស្ថាប័នពាក់ព័ន្ធ ត្រូវប្រតិបត្តិតាមសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.គណៈអចិន្ត្រៃយ៍ គ.ក.**
**អនុប្រធាន**

**សាយ ឈុំ**